ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ...០៦៤ សជណ/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១

## សូមគោរពជូន

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

**កម្មវត្ថុ** : របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំលើកទី១៨នៃគណៈកម្មការធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC)

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា នាព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំកិច្ចប្រជុំលើកទី១៨នៃគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្រោមអធិបតីភាពរបស់ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះបានធ្វើការពិភាក្សាទៅលើរបៀបវារៈសំខាន់ៗដូចខាងក្រោម :

១-) យុទ្ធសាស្ត្រជាតិ គាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និងការធានាឱ្យបាននូវការអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព

២-) វឌ្ឍនភាពនៃការធ្វើសុខដុមនីយកម្មរវាងការងារផែនការ ថវិកា និងហិរញ្ញប្បទានសហប្រតិបត្តិការ

៣-) ទម្រង់ និងដំណើរការនៃការគ្រប់គ្រងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូ អភិវឌ្ឍន៍ និង

៤-) បញ្ហាផ្សេងៗ។

នៅក្នុងរបៀបវារៈផ្សេងៗនៃកិច្ចប្រជុំនេះ រូបខ្ញុំបាទត្រូវបានអនុញ្ញាតិឱ្យធ្វើសេចក្តីរាយការណ៍ជាសង្ខេបអំពីវឌ្ឍនភាពនៃកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលសេចក្តីរាយការណ៍សង្ខេបរបស់ខ្ញុំបាទបានផ្តោតជាសំខាន់ទៅលើការរៀបចំ និងការអនុម័ត**ផអ៣** ការវាយតម្លៃរួមគ្នាដោយដៃគូអភិវឌ្ឍន៍លើឯកសារ **ផអ៣** ស្ថានភាពនៃហិរញ្ញប្បទានគាំទ្រ**ផអ៣** ការរៀបចំអនុស្សរណៈស្តីពីវិធីសាស្ត្រគ្រប់គ្រងទូទាំងកម្មវិធី និងសមិទ្ធិផលសំខាន់ៗនៃការអនុវត្ត**ផអ៣**នៅក្នុងត្រីមាសទី១នៃឆ្នាំ២០១១នេះ។

ជារួម ក្នុងកិច្ចដំណើរការនៃការពិភាក្សាលើរបៀបវារៈបីខាងលើ តំណាងដៃគូអភិវឌ្ឍសំខាន់ៗមួយចំនួនដូចជា ប្រធានធនាគារពិភពលោក តំណាងស្ថានទូតអាមេរិក តំណាងស្ថានទូតស៊ុយអែត និងតំណាងអង្គការមិនមែនរដ្ឋាភិបាល បានលើកឡើងនូវបញ្ហារសើបសំខាន់ៗចំនួនពីរ គឺ ១.) <u>បញ្ហាគ្រប់គ្រងដីធ្លី ជាពិសេសគឺបញ្ហាដីធ្លីនៅ</u>

តំបន់បឹងកក់ ២.) បញ្ហានៃច្បាប់ស្តីពីការគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល។ ពាក់ព័ន្ធនឹងបញ្ហានេះ ឯកឧត្តមប្រធានអង្គប្រជុំបានជម្រាបជូនអង្គប្រជុំថា រាជរដ្ឋាភិបាលបាន និងកំពុងគិតគូរលើបញ្ហាទាំងនេះ ដើម្បីធានាឱ្យមានដំណោះស្រាយល្អមួយសម្រាប់រយៈពេលយូរអង្វែង។

អាស្រ័យដូចបានជម្រាបជូនដោយសង្ខេបខាងលើ សូមឯកឧត្តមមេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**និង**

**ជាប្រធានក្រុមការងារបច្ចេកទេសទីមជ្ឈការ និងវិសហមជ្ឈការ**